## Oneida Indian Nation
## ប្រកាសព័ត៌មានលម្អិតនៃការអភិវឌ្ឍជាមួយទឹកប្រាក់ $370 លានដុល្លារ ជាការពង្រីកដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្ររមណីយដ្ឋាន

## គម្រោងពង្រីករយៈពេលពីរឆ្នាំ រួមមានមជ្ឈមណ្ឌលសន្និសីទថ្មី សណ្ឋាគារថ្មី និងច្រើនទៀត

*The Oneida Indian Nation ថ្ងៃនេះបានប្រកាសព័ត៌មានលម្អិតនៃការវិនិយោគដែលមានដើមទុន $370 លានដុល្លាររបស់ខ្លួនក្នុងការអភិវឌ្ឍរបស់ Turning Stone Resort Casino ដែលជាចំនួនទឹកប្រាក់ដ៏ធំបំផុតក្នុងប្រវត្តិសាស្ត្ររមណីយដ្ឋាន។* ការផ្លាស់ប្តូររយៈពេលពីរឆ្នាំនឹងរួមបញ្ចូលមជ្ឈមណ្ឌលសន្និសីទថ្មី កន្លែងសម្រាប់រៀបចំព្រឹត្តិការណ៍ខាងក្រៅ សណ្ឋាគារ និងជាច្រើនទៀត។ ការអភិវឌ្ឍនេះបន្តនូវការប្តេជ្ញាចិត្តរបស់ Oneida Indian Nation ចំពោះការវិនិយោគក្នុងតំបន់សហគ្រាស និងសមាជិកក្រុមរបស់ខ្លួនជាមួយនឹងការផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចមួយដងចំនួន $616 លានដុល្លារ ការបង្កើតការងារមួយដងបាន 3,600 កន្លែង និងទឹកប្រាក់ចំនួន $22.1 លានដុល្លារចំពោះប្រាក់ចំណូលពន្ធរដ្ឋ និងពន្ធក្នុងស្រុក។

**Oneida Indian Nation Homelands (ថ្ងៃទី 21 ខែកក្កដា ឆ្នាំ 2023) –** The Oneida Indian Nation ថ្ងៃនេះបានប្រកាសព័ត៌មានលម្អិតនៃការវិនិយោគដែលមានដើមទុនចំនួន $370 លានដុល្លាររបស់ខ្លួនក្នុងការអភិវឌ្ឍដ៏ធំបំផុតរបស់ Turning Stone Resort Casino ក្នុងរយៈពេលពីរទសវត្សរ៍នេះ។ លើសពីការពង្រីក ការវិនិយោគឡើងវិញនេះនឹងក្លាយជាការអភិវឌ្ឍពេញលេញនៃគោលដៅរមណីយដ្ឋានសំខាន់ក្នុងតំបន់ ដែលមានមជ្ឈមណ្ឌលសន្និសីទថ្មី កន្លែងរៀបចំព្រឹត្តិការណ៍ខាងក្រៅ សណ្ឋាគារ និងអ្វីៗជាច្រើនទៀតដើម្បីបំពេញក្តីស្រមៃឡើងវិញឱ្យបានពេញលេញនៃ Turning Stone សម្រាប់មនុស្សជំនាន់ក្រោយ។ The Nation បានចាប់ដៃគូជាមួយក្រុមហ៊ុនស្ថាបត្យកម្ម និងក្រុមហ៊ុនរចនាដ៏ល្បីល្បាញលើពិភពលោក Gensler ហើយនឹងចាប់ផ្តើមគម្រោងដ៏ធំរយៈពេលពីរឆ្នាំនេះនៅដើមឆ្នាំក្រោយ។ រួមជាមួយនឹងការវិនិយោគឡើងវិញចំនួន $370 លានដុល្លារ ការអភិវឌ្ឍរបស់ Turning Stone នឹងផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចមួយដងចំនួន $616

លានដុល្លារ បង្កើតការងារមួយដងបាន 3,600 កន្លែង និងបង្កើតចំណូលពន្ធរដ្ឋ និងពន្ធក្នុងស្រុកចំនួន $22.1 លានដុល្លារ។

(ការបង្ហាញពីការអភិវឌ្ឍរបស់ Turning Stone )

**មជ្ឈមណ្ឌលសន្និសីទថ្មីទំហំ 77,000 ហ្វីតការ៉េ**

ការអភិវឌ្ឍរបស់ Turning Stone នឹងកើនឡើងទ្វេដងនូវកន្លែងសន្និសីទដែលមានស្រាប់ជាមួយនឹងកន្លែងសម្រាប់រៀបចំព្រឹត្តិការណ៍ខាងក្នុង និងខាងក្រៅថ្មីដែលរួមមាន៖

- បន្ទប់ប្រជុំថ្មីចំនួនប្រាំបី ដែលភាគច្រើនមានបន្ទប់លំហែរខាងក្រៅ
- សាលថ្មីចំនួនពីរ រួមទាំងទំហំ 30,000 ហ្វីតការ៉េ Grand Ballroom ដែលអាចមើលទេសភាពពីខាងលើយ៉ាងស្រស់ស្អាតចំពោះ Shenendoah Golf Course និង The Lodge’s Great Lawn
- ទីធ្លាខាងក្រៅដែលមានកន្លែងរៀបចំព្រឹត្តិការណ៍ថ្មីៗចំនួនបី
- កន្លែងចតរថយន្តខាងក្នុងថ្មីមួយដែលអាចផ្ទុករថយន្តចំនួន 2,000 គ្រឿង និងងាយស្រួលចូលទៅកាន់មជ្ឈមណ្ឌលសន្និសីទ

នៅពេលបញ្ចប់ គ្រឿងបរិក្ខារថ្មីទាំងនេះនឹងធ្វើឱ្យ Turning Stone ជាមជ្ឈមណ្ឌលសន្និបាតធំជាងគេបំផុតនៅ Upstate New York និងជាកន្លែងមួយក្នុងចំណោមកន្លែងចំនួនបីដែលមានទំហំដូចគ្នានៅក្នុងរដ្ឋ។ រួមជាមួយនឹងសម្ភារបរិក្ខារ និងភាពជាដៃគូដែលមានស្រាប់ មជ្ឈមណ្ឌលសន្និសីទថ្មីនឹងពង្រីកការធ្វើទីផ្សាររបស់រមណីយដ្ឋាន និងតំបន់ជុំវិញ Mid-Atlantic និង New England និងឧស្សាហកម្មថ្មីៗ ដោយទាក់ទាញស្ថាប័ន និងព្រឹត្តិការណ៍កាន់តែធំ និងកាន់តែល្បីល្បាញមកទីនេះ។

**សណ្ឋាគារថ្មី ភោជនីយដ្ឋានថ្មី និងការធ្វើបច្ចុប្បន្នភាពយ៉ាងទូលំទូលាយទៅលើកន្លែងស្នាក់នៅដែលមានស្រាប់**

ដើម្បីសម្រួលដល់ការកើនឡើងនៃភ្ញៀវដែលចូលរួមក្នុងសន្និសីទ និងព្រឹត្តិការណ៍ផ្សេងៗ ការអភិវឌ្ឍក៏នឹងរួមបញ្ចូលការសាងសង់ The Crescent ផងដែរ។ សណ្ឋាគារលំដាប់ពេជ្របួនថ្មីនឹងស្វាគមន៍ភ្ញៀវជាមួយនឹងស្ថាបត្យកម្មដ៏អស្ចារ្យសម្រាប់ការចាប់អារម្មណ៍ និងលក្ខណៈពិសេសដែលមិនអាចបំភ្លេចបាន៖

- មាន 258 បន្ទប់ រួមទាំងបន្ទប់ធំទូលាយដែលមានគ្រែមួយ និងបន្ទប់គ្រែពីរចំនួន 23 បន្ទប់ធំសម្រាប់បទពិសោធន៍កាន់តែអស្ចារ្យ
- កន្លែងទទួលភ្ញៀវដែលមានភ្លើងកម្ដៅ ជាមួយកន្លែងអង្គុយ ហាងកាហ្វេសេវាកម្មរហ័ស និងកន្លែងអង្គុយ VIP
- Salt Seafood & Raw Bar គឺជាកន្លែងទទួលទានអាហារឆ្ងាញ់ថ្មីបំផុតពីក្រុមធ្វើម្ហូបដែលឈ្នះពានរង្វាន់របស់

Turning Stone ជាមួយនឹងបន្ទប់ទទួលទានអាហារលក្ខណៈឯកជនចំនួនប្រាំដែលអាចមើលទេសភាពខាងក្រៅបានយ៉ាងស្រស់ស្អាត

កន្លែងស្នាក់នៅដែលមានស្រាប់នៅ Turning Stone ក៏នឹងមានការផ្លាស់ប្តូរ ផងដែរ ដោយការជួសជុលនៅតែបន្តធ្វើនៅ The Lodge ដើម្បីរក្សាស្តង់ដារឈ្នះពានរង្វាន់ផ្កាយបួនរបស់ Forbes និង The Hotel ក្លាយជា The Brook ដោយយកឈ្មោះថ្មីក្នុងការគោរពចំពោះផ្លូវទឹកដ៏ស្រស់ស្អាតក្នុងតំបន់ និងផ្តល់នូវសោភ័ណភាពទំនើបទាន់សម័យ និងស្រស់ស្រាយ។

**NY Rec & Social Club មកកាន់ Exit 33**

នៅខែធ្នូ ឆ្នាំ 2023 The Lounge with Caesars Sportsbook នឹងផ្លាស់ប្តូរទៅជាគោលដៅជីវិតពេលរាត្រីចុងក្រោយបំផុតនៅ Turning Stone's Exit 33, NY Rec & Social Club (អតីត Lava Nightclub)។ ទិសដៅកម្សាន្តថ្មីនឹងផ្តល់ជូននូវបទពិសោធន៍គ្មានដែនកំណត់ជាមួយនឹងបរិក្ខារទំនើបៗដែលរួមមានៈ

- អេក្រង់ដែលមានគុណភាពបង្ហាញខ្ពស់ ជាង 60 គ្រឿង
- កន្លែងអង្គុយដ៏ប្រណិត
- កន្លែងអង្គុយដែលមានកង្ហារដ៏ត្រជាក់ស្រួល
- ជម្រើសហ្គេមលេងកម្សាន្តដែលរួមមាន តាប (ប៊ីយ៉ា), foosball, shuffleboard និង arcade
- បន្ទប់លំហែរខាងក្រៅដែលមានរណ្តៅសម្រាប់ដុតភ្លើង កន្លែងអង្គុយមានផាសុកភាព និងតាបសម្រាប់លេងបៀរ

**មជ្ឈមណ្ឌលវេជ្ជសាស្ត្រនៅនឹងកន្លែងសម្រាប់បុគ្គលិក និងភ្ញៀវ**

បទពិសោធន៍សមាជិកក្រុមនៅ Turning Stone និងនៅសហគ្រាសទាំងមូលរបស់ Nation នឹងបន្តវិវឌ្ឍផងដែរជាមួយនឹងការសាងសង់មជ្ឈមណ្ឌលវេជ្ជសាស្ត្រដែលមានទំហំ 5,000 ហ្វីតការ៉េ។ បង្កើតឡើងក្នុងភាពជាដៃគូជាមួយ Rome Health និងអាចចូលដំណើរការបានសម្រាប់សមាជិកក្រុមទាំងអស់ ក្រុមគ្រួសារ និងភ្ញៀវរមណីយដ្ឋានរបស់ពួកគេ មជ្ឈមណ្ឌលវេជ្ជសាស្ត្រនឹងផ្តល់ការថែទាំបន្ទាន់ បឋមភាពងាយស្រួល និងជំងឺបេះដូង ជាមួយនឹងម៉ោងបន្ថែមដែលគ្របដណ្តប់ពេលល្ងាច ចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក។

**ការបន្ថែមផ្សេងៗទៀតទៅ Turning Stone**

- Robert Trent Jones Jr.- តំបន់ហាត់វាយកូនហ្គោលត្រូវបានរចនាឡើងជាមួយនឹងកន្លែងបើកបរ និងតំបន់សម្រាប់លេងហ្គេមរយៈពេលខ្លី ដើម្បីគាំទ្រដល់ទីលានវាយកូនហ្គោលជើងឯករបស់រមណីយដ្ឋាន

- ឧបករណ៍សាករថយន្តអគ្គិសនីជាង 120 គ្រឿង ក្នុងនោះមាន 36 គ្រឿង Tesla Superchargers (ឆ្នាំងសាករថយន្តអគ្គិសនី) ត្រូវបានដំឡើងនៅក្នុងទឹកដី Nation ទាំងមូល ក្នុងភាពជាដៃគូជាមួយ Tesla សម្រាប់ភ្ញៀវ និងបុគ្គលិក

**<u>Oneida Nation Enterprises ក្លាយជា Turning Stone Enterprises</u>**

នៅក្នុងការទទួលស្គាល់នៃការអភិវឌ្ឍថេរដែលបានកំណត់សហគ្រាសរបស់ Oneida Indian Nation រយៈពេលបីទសវត្សរ៍ Oneida Nation Enterprises ដែលជាស្ថាប័នមេសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ Nation ក៏នឹងមានការអភិវឌ្ឍផងដែរ។ នៅថ្ងៃទី 1 នៃខែតុលា Oneida Nation Enterprises នឹងក្លាយជា Turning Stone Enterprises។ អត្តសញ្ញាណស្ថាប័នថ្មីទទួលស្គាល់តួនាទីសំខាន់របស់ Turning Stone ក្នុងការកំណត់ស្តង់ដារសម្រាប់សហគ្រាសទាំងអស់របស់ Oneida Indian Nation និងការរួមចំណែកសំខាន់ៗរបស់សមាជិកក្រុមគ្រប់រូប ដោយមិនគិតពីកន្លែងដែលពួកគេធ្វើការ ក្នុងការបង្កើត និងលើកកម្ពស់ស្តង់ដារនេះ។

**<u>អត្ថប្រយោជន៍ដល់ផ្នែកសេដ្ឋកិច្ចរបស់ Turning Stone និង Oneida Indian Nation</u>**

ចាប់តាំងពីការបង្កើតកាលពី 30 ឆ្នាំមកនេះ Turning Stone បានបម្រើការជាម៉ាស៊ីនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការបង្កើតការងារនៅក្នុង Upstate New York។ ការវិភាគអត្ថប្រយោជន៍សេដ្ឋកិច្ចធ្វើឡើងដោយ Oxford Economics ដែលជាក្រុមហ៊ុនផ្តល់ប្រឹក្សាសកលឯករាជ្យមួយក្នុងចំណោមក្រុមហ៊ុនប្រឹក្សាសកលដែលឯករាជ្យបំផុតរបស់ពិភពលោកបានរាយការណ៍ថាសម្រាប់នៅតែក្នុងឆ្នាំ 2022 ប៉ុណ្ណោះ Turning Stone និងសហគ្រាសផ្សេងៗរបស់ Oneida Indian Nation បានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចជាង $1 ប៊ីលានដុល្លារនៅក្នុងតំបន់ ហើយជារៀងរាល់ឆ្នាំបានគាំទ្រការងារជាង 7,000 កន្លែង រួមទាំងបុគ្គលិករបស់ Nation ចំនួន 4,500 នាក់។ ការវិនិយោគទឹកប្រាក់ $370 លានដុល្លារលើការអភិវឌ្ឍរបស់ Turning Stone នឹងបង្កើតការងារសំណង់រាប់ពាន់ និងប្រាក់ចំណូលរាប់លានដុល្លារផងដែរ ដោយសារតែការកើនឡើងនៃភ្ញៀវ និងទេសចរណ៍ក្នុងតំបន់ដែលត្រូវអនុវត្តតាម។

ឆ្នាំ 2023 ក៏ជាខួបលើកទី 10 នៃប្រវត្តិសាស្ត្រផងដែរ Settlement Agreement រវាង Oneida Indian Nation, New York State និង Oneida និងខោនធី Madison ។ ចាប់តាំងពីការអនុម័តរបស់ខ្លួន កិច្ចព្រមព្រៀងនេះបានផ្តល់ប្រាក់រាប់រយលានដុល្លារសម្រាប់សហគមន៍ក្នុងមូលដ្ឋាន និងបានជួយបង្កើតភាពជាដៃគូដ៏រឹងមាំរវាង Nation និងរដ្ឋាភិបាល និងអាជីវកម្មក្នុងតំបន់។ ភាពជាដៃគូទាំងនេះបានដើរតួយ៉ាងសំខាន់ក្នុងភាពជោគជ័យទៅវិញទៅមករបស់ Oneida Indian Nation និងតំបន់ ហើយនឹងបន្តដូច្នេះសម្រាប់រយៈពេល 30 ឆ្នាំខាងមុខ និងលើសពីនេះទៀត។

Ray Halbritter ជាតំណាង Oneida Indian Nation Representative និងនាយកប្រតិបត្តិ Oneida Nation Enterprises CEO បាននិយាយថា “Turning Stone Evolution មានច្រើនជាងការពង្រីក” ។

“វាមិនមានអ្វីក្រៅពីចង់បានការអភិវឌ្ឍពេញលេញនៃគោលដៅចម្បងរបស់តំបន់ និងតួនាទីរបស់ខ្លួនជាអ្នកដឹកនាំសេដ្ឋកិច្ច។ រួមជាមួយនឹងសម្ភារបរិក្ខារ និងភាពជាដៃគូដែលមានស្រាប់របស់យើង មជ្ឈមណ្ឌលសន្និសីទថ្មីនឹងធ្វើឱ្យ Turning Stone និង Central New York ជាគោលដៅដែលគួរឱ្យចង់បានកាន់តែច្រើនសម្រាប់ព្រឹត្តិការណ៍ធំៗ និងមានកិត្យានុភាព”។

**អំពី Turning Stone Resort Casino**

រមណីយដ្ឋានគោលដៅដែលទទួលបានពានរង្វាន់ដ៏ល្បីមួយនៅក្នុងតំបន់ Upstate New York, Turning Stone Resort Casino របស់ Oneida Indian Nation បំពាក់ដោយគ្រឿងបរិក្ខារលំដាប់ពិភពលោក រួមមានសណ្ឋាគារចំនួនប្រាំ ស្ប៉ាដ៏ប្រណិតចំនួនពីរ ទីលានវាយកូនហ្គោលចំនួនប្រាំ ជម្រើសអាហារច្រើនជាង 20 ជម្រើស កន្លែងលេងហ្គេមស្ទាយ Las Vegas ចំនួន 125,000 ហ្វីតការ៉េ The Lounge ជាមួយ Caesars Sports កន្លែងភ្នាល់កីឡាទំនើបទាន់សម័យ The Showroom កន្លែងប្រគុំតន្ត្រីដ៏ស្និទ្ធស្នាល កីឡដ្ឋានដែលមានកន្លែងអង្គុយចំនួន 5,000 កៅអី និងកន្លែងកម្សាន្តពេលរាត្រីជាច្រើនទៀត។ មានទីតាំងងាយស្រួលរកគឺចម្ងាយ 30 ម៉ាយពីខាងកើត Syracuse តាមអាសយដ្ឋាន NYS Thruway exit 33, Turning Stone ត្រូវបានដាក់ឈ្មោះថាកន្លែងលេងហ្គេមដ៏ល្អបំផុតលេខ #1 នៅ New York ដោយ Casino Player Magazine (ទស្សនាវដ្តី) និងជាកន្លែងទទួលទានអាហាររួមល្អបំផុតលេខ #1។  Turning Stone ក៏ទទួលបានពានរង្វាន់ Forbes Four-Star Award ដ៏មានកិត្យានុភាពផងដែរសម្រាប់ភោជនីយដ្ឋាន The Lodge,  Wildflowers, TS Steakhouse និង Skʌ:nʎ: Spa និងជាងមួយទសវត្សរ៍ ពានរង្វាន់ពេជ្របួន AAA សម្រាប់ The Lodge, The Tower Hotel, និងភោជនីយដ្ឋាន Wildflowers ។